អន្តរឃ្លាំ
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ រូបភាពទឹកមុខញញឹមក្នុងសម័យមហានគរជាភស្តុតាងបញ្ជាក់ថា ជនជាតិខ្មែរមានចរិយាស្លូតបូតសុភាពរាបសា ប៉ុន្តែម៉ឺងម៉ាត់ក្នុងការងារ ។

www.hoksavann.org

ថ្ងៃទី៣១ ធ្នូ ២០១២



«សម័យមហានគរ» បានត្រូវគេចាត់ទុកថា ជាសម័យចំរើនរុងរឿង មានទឹកដីធំទូលំទូលាយ មានអារ្យធម៌ខ្ពង់ខ្ពស់ ហើយបានជះឥទ្ធិពលរបស់ខ្លួនទៅលើប្រទេសជិតខាងទៀតផង ។ រូបសំណាកមួយ ដែលគេចាត់ទុកថា ជារូបរបស់ព្រះបាទជ័យវរ្ម័នទី៧ មានព្រះភ័ក្ត្រញញឹមស្ងប់បែបចិត្តជាសមាធិ និងប្រកបដោយគតិបណ្ឌិតយ៉ាងជ្រាលជ្រៅ ។ ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គប្រតិបត្តិតាមព្រះពុទ្ធសាសនាមហាយាន ជាសាសនាមានលក្ខណៈកាន់ធម៌អហិង្សាការមិនបៀតបៀន ។ ភាពញញឹមនេះ ពិតជាព្រះអង្គប្រតិបត្តិតាមព្រហ្មវិហារ មេត្តា ករុណា មុទិតា និងឧបេក្ខា ជាគោលធម៌ដែលព្រះអង្គអនុវត្ត ដើម្បីសេចក្តីសុខសាន្តដល់ប្រជាពលរដ្ឋរបស់ព្រះអង្គ ។ ព្រហ្មវិហារទាំង៤នេះហើយ ជាធម៌ញុំាងឲ្យប្រជារាស្ត្រសាមគ្គីជាមួយព្រះអង្គរួបរួមគ្នាដើម្បីការពារ និងអភិវឌ្ឍន៍ប្រទេស ឲ្យមានសន្តិភាពនិងចំរើនលូតលាស់ ។ ព្រះមហាក្សត្រនិងប្រជារាស្ត្រនៅក្រោមធម៌ព្រហ្មវិហារនេះហើយ បានធ្វើឲ្យព្រះរាជាណាចក្រកម្ពុជាពេលនោះមានភាពរឹងមាំ ដែលសត្រូវមិនអាចបំបែកបាន ។ អ្នកស្រាវជ្រាវប្រវត្តិរបស់ព្រះអង្គយល់ឃើញថា ព្រះបាទជ័យវរ្ម័នទី៧ពិតជាអនុវត្តតាមទសពិធរាជធម៌ ជាធម៌ដែលព្រះមហាក្សត្រត្រូវប្រតិបត្តិតាម ដែលព្រះពុទ្ធសមណគោតមបានសំដែងជាធម៌ ធ្វើឲ្យអ្នកប្រតិបត្តិតាម ទៅជាព្រះមហាក្សត្រពិតប្រាកដ ។ គេយល់ថា បើព្រះអង្គពុំបានប្រតិបត្តិតាមឲ្យគ្រប់ទាំង១០ទេ ក៏គង់ប្រតិបត្តិតាមបានភាគច្រើនដែរ ។

ពេលនេះយើងសូមអនុញ្ញាតលើកយកទសពិធរាជធម៌ទាំង១០នេះ មកបញ្ជាក់ដូចតទៅនេះ ៖

១- «ទានៈ» ការធ្វើអំណោយដល់ប្រជារាស្ត្រក្រខ្សត់អត់ឃ្លាន ដោយព្រះទ័យអាណិតអាសូរ ។

២- «សីលៈ» ការរក្សាសីល៥ជាប់ជានិច្ច និងរក្សាសីល៨តាមកាលកំណត់ ។

៣- «បរិច្ចាគៈ» ការចំណាយព្រះរាជទ្រព្យកសាងប្រទេស និងឧបត្ថម្ភព្រះពុទ្ធសាសនា គឺសំរាប់បណ្តុះបណ្តាលសីលធម៌ ឲ្យមានវឌ្ឍនភាព ទន្ទឹមគ្នានឹងការលូតលាស់ខាងសេដ្ឋកិច្ចជាតិ ។

៤- «អាជ្ជវៈ» សេចក្តីទៀងត្រង់ឬស្មោះត្រង់ចំពោះប្រជារាស្ត្រគ្រប់កិច្ចការ ដែលអនុវត្តធ្វើឬបញ្ជាឲ្យធ្វើ គឺស្របទៅតាមផលប្រយោជន៍នៃប្រជារាស្ត្រ ដោយព្រះទ័យស្មោះត្រង់ ។

៥- «មទ្ទវៈ» មានសភាពទន់ភ្លន់ សុភាពរាបសា ទៅកាន់ប្រជារាស្ត្រ គឺមានសេចក្តីរាប់អានប្រជារាស្ត្រទូទៅ ដូចជាបុត្របង្កើត ។ បានសេចក្តីថា មិនប្រកាន់ តែងតែមានការស្និទ្ធិស្នាលជានិច្ច ទៅលើពលរដ្ឋទូទៅ តែងមានការសន្ទនាដកស្រង់យកយោបល់របស់ប្រជារាស្ត្រ ដើម្បីរៀបចំផែនការស្រុកទេសឲ្យមានយុត្តិធម៌ ។

៦- «តបៈ» អប់រំព្រះទ័យដោយសមាធិចិត្ត ដើម្បីបន្ថយនូវកាមារម្មណ៍ គឺបន្ថយនូវការសប្បាយក្នុងរូប សម្លេង ក្លិន រស និងសម្ផស្ស ធ្វើព្រះទ័យឲ្យស្ងប់ចាកកាម ដោយហោចក្នុងថ្ងៃឧបោសថ ។

៧- «អក្កោធនៈ» មិនក្រេវក្រោធ មិនធ្វើឲ្យប្រជារាស្ត្រឬមនុស្សទូទៅក្តៅក្រហាយ គឺរម្ងាប់ក្តីកំហឹង មិនក្រោធតបនូវមនុស្សដែលក្រេវក្រោធ ។

៨- «អវិហឹសា» មិនបៀតបៀនប្រជារាស្ត្រនិងមនុស្សទូទៅ គឺមិនធ្វើឲ្យប្រជារាស្ត្រមានទុក្ខតាមផ្លូវកាយនិងចិត្ត តែមានព្រះទ័យករុណា អាណិតអាសូរ ជួយដោះស្រាយគ្រប់បញ្ហាទុក្ខលំបាកគ្រប់យ៉ាង និងអត់ធន់ចំពោះពាក្យរិះគន់គ្រប់បែប មិនតបតដោយអំពើហិង្សាឡើយ ។

៩- «ខន្តិ» អត់ធន់ចំពោះរាជកិច្ចគ្រប់យ៉ាង ដែលជាភារកិច្ចរបស់ព្រះអង្គដែលត្រូវបំពេញ ទោះបីមានការលំបាក ។

១០- «អវិរោធនៈ» មិនបំពានច្បាប់ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួនព្រះអង្គ និងប្រយោជន៍ព្រះញាតិ ដើម្បីប្រយោជន៍ជាតិ ។ មិនរំលោភច្បាប់ធម៌ និងច្បាប់របស់រដ្ឋ ។

ទសពិធរាជធម៌ទាំង១០ប្រការនេះ ពុំមែនប្រតិបត្តិតែព្រះមហាក្សត្រទេ អ្នកដឹកនាំរដ្ឋជាន់ខ្ពស់ដទៃទៀតក៏ត្រូវអនុវត្តដូចគ្នា ព្រោះរាជៈនេះ ពុំមែនសំដៅតែព្រះមហាក្សត្រសោយរាជ្យទេ គឺសំដៅដល់ជនណាដែលធ្វើឲ្យប្រជារាស្ត្រត្រេកអរបាន គឺត្រេកអរដោយសារមានការធ្វើឲ្យជាតិអភិវឌ្ឍន៍គ្រប់វិស័យ មានវិស័យសង្គមកិច្ចនិងវប្បធម៌ជាដើម ដោយសារប្រតិបត្តិតាមទសពិធរាជធម៌ទាំង១០ប្រការនេះឯង ។ តាមន័យនេះ ជនណាក៏អាចធ្វើជាព្រះមហាក្សត្របានដែរ ឲ្យតែប្រតិបត្តិបានត្រឹមត្រូវតាមទសពិធរាជធម៌ទាំង១០ប្រការនេះ ។ បើប្រតិបត្តិតាមមិនបានទេ មិនអាចធ្វើជាព្រះមហាក្សត្រ ឬអ្នកដឹកនាំជាន់ខ្ពស់បានឡើយ ។

ព្រះពុទ្ធសាសនាសំដែងថា ទំនាបនិងកំពស់របស់មនុស្ស ត្រូវស្ថិតនៅលើអំពើអាក្រក់និងអំពើល្អដែលគេបានប្រព្រឹត្ត ពុំមែនស្ថិតនៅលើជាតិត្រកូល ទ្រព្យសម្បត្តិ យសស័ក្តិឡើយ ។ សូមបញ្ជាក់ថា កាលពីសម័យដើម ជាពិសេសសម័យពុទ្ធកាល អ្នកកាន់អំណាចរដ្ឋគឺស្ថិតនៅលើព្រះមហាក្សត្រ ពុំមែនដូចជាសម័យសព្វថ្ងៃនេះ អ្នកកាន់អំណាចរដ្ឋស្ថិតនៅលើប្រធានាធិបតី ប្រមុខរដ្ឋ ឬនាយករដ្ឋមន្ត្រី ។ បានជាព្រះមហាក្សត្រត្រូវបានបាត់បង់អំណាចជាបន្តបន្ទាប់គ្នា ព្រោះពុំគោរពតាម

ទសពិធរាជធម៌ទាំង១០ប្រការនេះ ។ សព្វថ្ងៃនេះមានសល់ខ្លះតែមិនកាន់អំណាច ដូចជាប្រទេសជប៉ុន ប្រទេសកម្ពុជាជាដើម ។ ទសពិធរាជធម៌ទាំង១០ប្រការនេះ ខ្ពស់ជាងរបបប្រជាធិបតេយ្យ ដែលប្រទេសជឿនលឿនយកមកប្រើសព្វថ្ងៃនេះផង ។ បានសេចក្ដីថា បើមិនធ្វើតាមរបបប្រជាធិបតេយ្យនិងគោរពសិទ្ធិមនុស្ស ទុកដូចជាអ្នកកាន់អំណាចមិនធ្វើតាមទសពិធរាជធម៌ទាំង១០ប្រការនេះឯង ។

រួចមកហើយយើងបានឃើញថា សម័យមហានគរមានការជឿនលឿនគ្រប់វិស័យ ដោយស្ដាព្រះហស្ដព្រះបាទជ័យវរ្ម័នទី៧ មានព្រះភ័ក្រ្តញញឹម ប្រើអំណាចព្រះធម៌គ្រប់គ្រងប្រទេស អាចបង្រួបបង្រួមជាតិ បានដាក់ខ្លួនបំរើប្រជារាស្ត្រ សេចក្ដីទុក្ខរបស់ប្រជារាស្ត្រ ជាសេចក្ដីទុក្ខរបស់ព្រះអង្គ ធ្វើឲ្យជាតិបានសុខសន្តិភាព និងចំរើនលូតលាស់ ។ សម័យក្រោយមក ព្រះមហាក្សត្រ អ្នកកាន់រដ្ឋអំណាច មិនអនុវត្តតាមទសពិធរាជធម៌ទាំង១០នេះឲ្យបានពេញលេញ បានធ្វើឲ្យរាជាណាចក្រកម្ពុជាធ្លាក់ចុះ ខ្មែរបែកបាក់គ្នា ប្រទេសជិតខាងបានចូលមកឈ្លានពានប្រទេសកម្ពុជា រំលោភយកទឹកដីអស់ជាច្រើន ដោយខ្មែរម្នាងៗពឹងអំណាចបរទេស ដើម្បីឲ្យឈ្នះចាញ់ខ្មែរគ្នាឯង ។ រហូតមកទល់ពេលនេះ ប្រវត្តិសាស្ត្រនៅតែដដែល ចរិតអ្នកដឹកនាំខ្មែរមិនព្រមផ្លាស់ប្ដូរ ឃើញខ្មែរពុំមែនជាបក្សខ្លួន ដូចឃើញខ្មាំងសត្រូវដែលខ្លួនត្រូវតែកំចាត់។ ត្រូវតែនាំគ្នាគិតថា បើនាវាកម្ពុជាត្រូវលិច ខ្លួនក៏ត្រូវលិចស្លាប់ដែរ ។

ពេលនេះ មតិជាតិនិងអន្តរជាតិមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយឃើញតុលាការដ៏អយុត្តិធម៌មិនឯករាជ្យរបស់ប្រទេសកម្ពុជា ដែលកាត់សេចក្ដីដាក់ទោសដល់ពលរដ្ឋស្លូតត្រង់ដែលពុំមានទោស ។ ពលរដ្ឋខ្មែរដ៏អភ័ព្វនៅសល់បិខ្មែរក្រហមសម្លាប់ ឥឡូវនេះតុលាការកំពុងព្យាយាមធ្វើបាបពលរដ្ឋស្លូតត្រង់តទៅទៀត ។

អ្នកស្រីយ៉ោម-បុប្ផាតំបន់បឹងកក់ជាសកម្មជនការពារដីធ្លី ត្រូវតុលាការសាលាដំបូងរាជធានីភ្នំពេញ កាត់ទោសឲ្យជាប់ពន្ធនាគារចំនួន៣ឆ្នាំ ដែលគេមើលឃើញថា ជាការកាត់ទោសដោយអយុត្តិធម៌ ។ នៅថ្ងៃ២៧ ធ្នូ ២០១២ លោកប៊ិន-សំណាង និងសុក-សំអឿន ត្រូវសាលាឧទ្ធរណ៍រាជធានីភ្នំពេញកាត់ទោសឲ្យជាប់ពន្ធនាគារចំនួន២០ឆ្នាំជាថ្មីឡើងវិញ ដែលគេឃើញថា ជាការកាត់ទោសសិប្បនិមិត្តតាមផ្លូវនយោបាយ ហើយដើម្បីស្ដារកិត្តិយសរបស់សាលាដំបូង ដែលកាត់ទោសដូចគ្នានេះ ។

ប្រជាពលរដ្ឋស្លូតត្រង់កាត់ឲ្យមានទោស តែបែរជាបោះបង់ចោលការចោទប្រកាន់មេពេជ្ឈឃាតឈូក-បណ្ឌិត អភិបាលក្រុងបាវិត ដែលចុះពីរថយន្តទាញកាំភ្លើងបាញ់សំដៅទៅរកហ្វូងបាតុករពីក្រោយខ្នង ត្រូវរបួសកម្មការិនី៣នាក់ ។ យើងនិយាយដោយខ្លី បើចង់ស្ដារកិត្តិយសប្រទេសកម្ពុជា តុលាការត្រូវតែដោះលែងអ្នកស្រីយ៉ោម-បុប្ផា, លោកប៊ិន-សំណាង, លោកសុក-សំអឿន ដោយគ្មានលក្ខខ័ណ្ឌ ។ បញ្ហាមួយទៀត សហភាពសហជីពកម្ពុជាដឹកនាំដោយលោករ៉ុង-ឈុន និងសម្ព័ន្ធសហជីពកម្ពុជាដឹកនាំដោយលោកស្រីយ៉ាង-សុភ័ណ្ឌបានដឹកនាំបងប្អូនកម្មករ-កម្មការិនីធ្វើបាតុកម្មអហិង្សាទាមទារដម្លើងប្រាក់ខែគោលពី៦១ដុល្លារទៅ១៥០ដុល្លារក្នុង១ខែចាប់ពីឆ្នាំ២០១៣នេះតទៅ ។ យើងសូមគាំទ្រនូវការទាមទារដ៏សមរម្យនេះ ព្រោះប្រាក់ខែកម្មករខ្មែរទាបជាងប្រទេសដទៃ ។ កម្មករថៃ២៦៣ដុល្លារ, ហ្វីលីពីន២១២ដុល្លារ, ឥណ្ឌូណេស៊ី១៨២ដុល្លារ, វៀតណាម១៧២ដុល្លារ, ស្រីលង្កា១២០ដុល្លារ, ប៉ាគីស្ថាន១៧៨ដុល្លារ ។៚

*                    *

*